March 2016

# ការសន្យារបស់ AA

បើយើងខំប្រឹងយកចិត្តទុកដាក់ចំពោះតំណាក់ការនៃការអភិវឌ្ឍន៍របស់យើងនោះ យើងនឹងមាន ការស្ញើចសរសើរ មុនពេលយើងបានទៅដល់ពាកកណ្ដាលផ្លូវនៃការស្ដារឡើងវិញរបស់យើង។ យើងនឹងបានទទួលនូវសេរីភាពថ្មី និង សុភមង្គលថ្មី។ យើងនឹងមិនមានការសោកស្ដាយចំពោះ ពេលកន្លងមក ឬមិនប្រាថ្នាចង់បិទឱកាស ចំពោះការស្ដារឡើងវិញនេះ។ យើងនឹងស្វែងយល់ពី ពាក្យស្ងប់សុខ ហើយយើងនឹងបានស្គាល់ពីសន្តិភាពពិត។ មិនថាឡើយយើងបានធ្លាក់ដល់កំរិតទាបយ៉ាងណា យើងនឹងបានយល់ពីបទពិសោធន៍របស់យើងដែលអាចជាអត្ថប្រយោជន៍ដល់អ្នកដទៃ។ ការមានអាម្មណ៍ថាយើងជាមនុស្សឥតប្រយោជន៍ និង អារម្មណ៍តូចចិត្តអាណិតខ្លួនឯងបានរលាយបាត់ចេញពីយើងទៅ។ យើងលែងមានចំណាប់អារម្មណ៍ចំពោះការគិតពីប្រយោជន៍អាត្មានិយម និងការកេងចំណេញពីមិត្តរបស់យើង។ ការស្វែងរកប្រយោជន៍ផ្ទាល់ខ្លួននឹងត្រូវរលាយបាត់ពីយើងទៅ។ អាកប្បកិរិយាទាំងស្រុងនិងទស្សនៈយល់ឃើញពីជីវិតរបស់យើងនឹងមានការផ្លាស់ប្ដូរ។ ការខ្លាចមនុស្សនិងសន្តិសុខសេដ្ឋកិច្ចរបស់យើងនឹងមិននៅជិតជាប់នឹងយើងទៀតឡើយ។ យើងនឹងដឹងជាក់ច្បាស់ពីរបៀបដោះស្រាយស្ថានការណ៍ដែលធ្លាប់តែមកយាយីយើងនោះជាមិនខាន។ យើងភ្លាមនោះដឹងថាព្រះជាម្ចាស់កំពុងធ្វើការអ្វីដែលយើងខ្លួនឯងមិនអាចធ្វើបាន។

តើនេះជាការសន្យាដែលខ្ជះខ្ជាយលុយកាក់ឬ? យើងមិនគិតដូច្នោះឡើយ។ ការសន្យានោះមានគ្នាយើងខ្លះបានយោងទៅសម្រេចបានខ្លះហើយ ជួនកាលក៏សម្រេចបានយ៉ាងឆាប់ និងជួនកាលក៏សម្រេចបានយ៉ាងយូរដែរ។ ការសន្យានោះតែងតែបានទទួលផលជាក់ស្ដែង បើយើងខំប្រឹងធ្វើតាមសេចក្ដីសន្យានោះ។